FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ២ លេខ ០៩ ខែកុម្ភៈ ឆ្នាំ ២០០៣
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# រលាកស្រទបស្រូវ

## រលាកស្រទបស្រូវគឺជាអ្វី?

គឺជាជំងឺស្រូវម្យ៉ាងដែលបង្កឡើងដោយភ្នាក់ងារចំលងរបស់ផ្សិតឈ្មោះ *Rhizoctonia solani* ។

## តើវាមានរោគសញ្ញាយ៉ាងដូចម្តេច?

ជាទូទៅ យើងអាចសង្កេតឃើញរោគសញ្ញាណនៃជំងឺនេះចាប់ផ្តើមលេចចេញនៅដំណាក់កាលបែកគុម្ព រហូតដល់ដាក់ទឹកដោះ។ពោល គឺមានស្នាមអុចដាមជាប់នៅលើស្រទបនៃដើមស្រូវដែលមានទំហំ ១-៣សម រាងជារង្វង់ពងក្រពើ មានពណ៌ប្រផេះ និងនៅលើស្លឹក, កួរស្រូវមាន ស្នាមអុចពណ៌ប្រផេះនៅចំណុចកណ្តាល ហើយនៅគែមនៃចំនុចមាន ពណ៌ត្នោត។





## តើវារាលដាលយ៉ាងដូចម្តេច?

ជំងឺនេះរាលដាលខ្លាំងនៅពេលអាកាសធាតុក្តៅ និងមានសំណើមខ្ពស់។ មិនតែប៉ុណ្ណោះការប្រើជីអាសូតលើសកំរិត និងស្ទូងវីព្រោះមានដង់ស៊ីតេខ្ពស់ គឺជាមូលហេតុធ្វើអោយជំងឺមានការរីករាលដាលខ្លាំង។

## តើបច្ចុប្បន្នវាកើតមាននៅតំបន់ណាខ្លះ?

បច្ចុប្បន្ននេះវាកើតមាននៅគ្រប់តំបន់ទាំងអស់ក្នុងផលិតកម្មដំណាំស្រូវ។ ដូចជានៅប្រទេសហ្វីលីពីន, ឥណ្ឌា, ជប៉ុន, ចិន, វៀតណាម, ថៃ, កម្ពុជា។ល។

## តើមានវិធានការអ្វីខ្លះដើម្បីធ្វើការកំចាត់?

- **វិធានការបង្ការ**

១. ក្រោយពេលប្រមូលផលរួចចាំបាច់ត្រូវធ្វើការភ្ជួរដី និងត្រូវធ្វើការដាក់ជីកំប៉ុសទ្រាប់បាត ហើយត្រូវធ្វើការដាក់ជីគីមី (NPK) អោយបានត្រឹមត្រូវទៅតាមក៏រិតណែនាំ នៃប្រភេទដី។

២. ត្រូវធ្វើការជ្រើសរើសរកពូជដែលមានសុខភាពល្អ (ដោយអុំ, ស្ទៃ ឬ ដោយសូលុយស្យុងទឹកអំបិល)។

៣. បើសិនជាយើងសង្កេតឃើញមានវត្តមាននៃជំងឺរលាក់ស្រទបនៅលើគ្រាប់ស្រូវ យើងត្រូវធ្វើការ ប្រឡាក់ថ្នាំពុលកសិកម្ម (ថ្នាំសំលាប់ផ្សិត Fungicide) មុនពេលយកទៅសាប រឺព្រោះ ដោយត្រូវពិគ្រោះជាមួយអ្នកបច្ចេកទេស ផ្នែកការពារដំណាំ។

៤. ត្រូវធ្វើការកាត់បន្ថយនូវចំនួនដង់ស៊ីតេដើមស្រូវនៅក្នុងស្រែអោយបានសមស្រប និង ត្រូវធ្វើការបង្ហូទឹកចេញពីស្រែនៅដំណាក់កាលបែកគុម្ពអតិបរិមាចំនួន២-៣ថ្ងៃ។

៥. ត្រូវធ្វើការសំអាតស្មៅស្រែជាប្រចាំអោយបានស្អាត

៦. បើសិនជាជំងឺនេះមានការរីករាលខ្លាំង ត្រូវធ្វើការដុតកញ្ជ្រាំងក្នុងស្រែនោះចោល តែវិធានការនេះអាចធ្វើអោយមានផលប៉ះពាល់ដល់ មីក្រូសរីរាង្គ ដែលជាសារធាតុចាំបាច់សំរាប់ការលូតលាស់របស់រុក្ខជាតិ។

- **វិធានការកំចាត់**

១. ត្រូវធ្វើការដកចោលជាបន្ទាន់នូវដើមស្រូវណាដែលទទួលរងនូវការបំផ្លាញពីជំងឺរលាក់ស្រទាប់។

២. ត្រូវធ្វើការបាញ់ថ្នាំពុលកសិកម្ម carbendazim 50WP (1g/l) អោយស្របតាមការណែនាំរបស់អ្នកបច្ចេកទេសផ្នែកការពារដំណាំ។

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង កម្មវិធីការពារដំណាំ ឬមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ឬការិយាល័យពាណិជ្ជកម្ម និងសហប្រតិបត្តិការ នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ឬ តាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ.

ទូរស័ព្ទលេខ: (៨៥៥ ២៣ )៦៣១៩ ៦៩៣-៤ ទូរអក្ខរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh

PLAP@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh